ទស្សនាវដ្ដី លេខ ៥

# ពុទ្ធិកវិទ្យាល័យ



ទីចាត់ការ វត្តចេត្តា សង្កាត់លេខ ៦
ភ្នំពេញ

[illegible]

ព 128

128

# មាតិការឿង


| | | |
|---|---|---|
| ភិក្ខុ អាំ-សួន (ហៅហម). . | វិចារណកថា | ទំព័រទី ១ |
| បណ្ឌិត សម-សុខុម . . . | ពុទ្ធទស្សនៈ (ត) | ,, ៥ |
| . . . . . . | ដំណឹងសាសនា | ,, ៨ |
| មហា មាស-ចន. . . . . | ប្រវត្តិសង្ខេបនៃនាលន្ទា | ,, ១០ |
| លោក កែវ-ហាង់ . . . . | ពុទ្ធប្បវត្តិ | ,, ១២ |
| មហា ថោង-ទិត . . . . | ស្ថានការណ៍នៅសហភាពភូមា | ,, ១៦ |
| . . . . . . | ប្រអប់សំបុត្រ | ,, ១៨ |
| ភិក្ខុ អាំ-សួន (ហៅហម) . | របនាវិលាសវាក្យភាសាអង់គ្លេស | ,, ២៦ |
| លោក ប៉យ-ប៊ុក . . . . | រឿងតុក្កតាធ្វើពីទធិជាតិ (ត) | ,, ២៨ |
| លោក តែ-ផុន . . . . . | ជ័យប្រាជ្ញ (ត) | ,, ៣០ |
| លោក សួន-សុរិន្ទ . . . . | បុណ្ណកុមារ (ត) | ,, ៣២ |
| . . . . . . | ប្រវត្តិក្មេងកំព្រា | ,, ៣៥ |


## ថ្លៃទ្បជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលទ្បជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# វិចារណកថា

## ការសន្ទនាគ្នារវាងពពែនឹងស្វា ក្នុងឱកាសចូលឆ្នាំថ្មី ជាភាសាបាលី

វនរោ មក្កដោ សត្តោ
បត្តវរោ ឥទានេវ
តិដ្ឋន្តំ ឯឡកំ ទិស្វា
ឥតិ វត្វា តេន សទ្ធឹ
បុរិមចិត្រមាសាយ
រក្ខិតា ឯឡកេនេវ
អម្ហាកមេករដ្ឋស្ស
សីហានុ នាមកស្សេសោ
តស្ស វរោ អឌ្ឍនាទិ
វរស្សកគន្តុកស្សេវ
“មារិស មក្កដ សម្ម
កម្ពុជរដ្ឋសត្តានំ
ទឡ្ហី—ករកេរដ្ឋី វ
ឯតំ—សុវណ្ណរដ្ឋស្ស
តថា អម្ហាក រាជានោ
ការកោ រដ្ឋសេរិយោ

ហនុមានោ មហព្ពលោ
កម្ពុជរដ្ឋ មាគតោ ។
“សុប្បភាតំ មហាសម្ម!”
កថាសល្លាបមារភិ ។
យាវជុនា វ កម្ពុជា
សម្បន្នាយេវ សេរិយោ ។
នរោត្តមស្ស បិតុនោ
សេនាមច្ចា វរុត្តមោ ។
សោ ករោត្យានុសាសនំ
មក្កដស្ស ឥទ្ធិមតោ : ។
ករ កាលំ យោជ សមំ
កម្មន្តាយុជ្ជាបយំ ។
យំ មេ កតំ អាហាបយំ
គុណស្ស បយបស្សិវ ។
រាជបុត្តោ ច ធម្មិកោ
រក្ខិតព្វា តយា ហរេ ។

សាសនញ្ច ឥទំ ពុទ្ធ– ស្ស សុគតស្ស មុនិនោ
លោកហិតាវហំ រក្ខ វុឌ្ឍិ–សន្តិសុខាយតិ ” ។

ឯវំ សុត្វាន វ៉នពេ មហាពូណោ អសន្តាសោ
មុខស្សគ្គុបនំ ទស្សំ និគ្គយោ ច បជីវិធ:
“ឯវំ ឯវំ មហាសម្ព មា ភយ មា តសី–កវ
សព្វភាវំ កវិស្សាមិ កម្មជាយ វិសុទ្ធិយា ។
ជានាសិ ត្វំ បិយមិត្ត អទុតិយោម្ហិ មក្កជោ
ហន្ទុមាទោតិ នាមេន មហិទ្ធិកោ មហាពូណោ ។
មហាតេជោ វិរោ លោកេ សិប្បកម្មេសុ បគុណោ
មហាពជស្ស ពមស្ស ភូតបុព្វោ សេនាបតិ ។
រាវេ មេ ភាគតេខាទិ គោបេស្សាមេវ សាសនំ
ពជានោ យុវពជានំ រដ្ឋំ សេវិញ្ច ជនតំ ។

សុខំ ខេមំ ឥទំ សន្តំ សីតលំ ពុទ្ធសាសនំ
សទា សាមគ្គិមាហជំ យេសំ តស្ស សុរក្ខនំ ។
ពជា ច ពជិនី ចេវ នវរដ្ឋំ វ ការេតា
បិយា មនាម សព្វេសំ កម្ពោជរដ្ឋវាសិនំ ។
យុវពជា មហាវីរេ កម្ពុជរដ្ឋនាយកោ
មហាប្បញ្ញោ កល្យោ ទក្ខោ មហេសី ឯករដ្ឋស្ស ។
សព្វេសំ ការុណិកោ នាថោ មិហិតលក្ខណោ សុភោ

ការកោ ហិតកម្មស្ស ជនិប្ឋិតស្ស ហារកោ ។

ពហុកម្មោ អហោរត្តឹ ពលិក្កាពេ បដាហិតេ

អហាញ្ញស្ស មហាមច្ចោ រក្ខិតុំ តំ អនុប្បេ ។

កម្ពុជាយេវ រដ្ឋញ្ច វឌ្ឍេតុំ ភិយោ មយា

ធនេន អាការេន វ អភិនិប្ផាទនេន ច ។

រក្ខិតព្វញ្ច តំ សន្តិ- ភាវេ វារេ ជនក្កន្តេ

ធិតញ្ច វិបុលំ កត្វា គមនាគមនិកន្ទថា ។

តរុណេតស្ស សេរី បិ មុទុសន្តា អភិលទ្ធា

ភិយ្យោសោ វិបុលី-កត្វា និវារេតព្វ សត្តុហិ ។

កម្ពោជិកំ ជនតញ្ច កាលស្សេវ ឧដ្ឋាបយំ

កម្មន្តេ បយោជេយ្យំ សិក្ខនេន វារេន ច ។

ទណ្ឌកម្មំ ករិស្សាមិ យេហិ ទុច្ចរិតំ កតំ

សុកតំ យេហិ កម្មញ្ច សោត្ថិ តេសំ សមិជ្ឈតុ ។

ឯវំ បិយ មហាមិត្ត មមាទិស សន្ខុមុខ

សព្វេ មយ្ហំ ភាព ហោន្តុ សោធេស្សាមេវ សោត្ថិនាតិ ។

"សាធុ! សាធុ! បិយមិត្ត" ឥតិ កថេតិ ឯឡ្យកោ,

"សាធុកំ សុន្ទរេញ្ញាវ យំ តយា វុត្តវចនំ ។

តស្មា ហព្យាហំ មហាមិត្ត កពេមិ អបលោកនំ

សកដ្ឋានំ គមិស្សាមិ ករោហិ ត្វំ យថារុចិ ។

វិញ្ញត្ត ពុទ្ធជម្មោ វ! ហោតុ សព្វេ សមង្គិកោ!

ជយោ អម្ហាក សេញ្ញោ ច ហោតុ រាជិនិយោ តថា!

ជយោ ឧបយុវរាជស្ស ឯករដ្ឋស្ស បិតុនោ!

សោត្ថិ កម្ពុជរដ្ឋស្ស! តិដ្ឋតុ តំ អព្យាកតំ!

វិញ្ញត្តុ ទទ្ហិ-កវិតុ ឯករដ្ឋំ មនោរមំ!

ហោន្តុ វិញ្ញិ វិរុទ្ហិ ច សុខំ កម្ពុជវាសិនំ!!!”

ឥច្ចេវំ ឯឡ្យកោ វត្វា “សុវត្ថី និដ្ឋបយិ

គតោ ឯត្តន្តរហិត្វា សកដ្ឋានំ ឧបាគមិ ៗ

X

X X

ជម្ពូទីបេ នាលន្ទាមហាវិជ្ជាលយេ

កម្ពុជកោ វីរបណ្ឌិតោ នាម ភិក្ខុ

កម្ពុជិកនាមេន “អាំ-សួន, អាំ-ហម ឥតិបិញ្ញាតោ ៗ



## ពុទ្ធទស្សនៈ (ត)

ទុតិយជ្ឈានមានអង្គ៣គឺ:

លះវិតក្កនឹងវិចារចេញបាន នៅសល់តែបីតិសុខៈ នឹងឯកគ្គតា ។

តតិយជ្ឈានមានអង្គ២គឺ:

លះបីតិបាន នៅសល់តែសុខនឹងឯកគ្គតា ។

ចតុត្ថជ្ឈានមានអង្គពីរគឺ:

លះសុខបានក្លាយជាឧបេក្ខា ហើយនឹងឯកគ្គតា ។

បញ្ហា ៣ប្រការដែលពោលថា: បានកើតឡើងក្នុងហឫទ័យរបស់ព្រះពុទ្ធជាម្ចាស់ ក្នុងយាមទាំង៣ជាលំដាប់នោះ, លោកពោលទុកថា: ក្នុងយាមទី១កើតបុព្វេនិវា-

សានុស្សតិញាណ ប្រែថា សេចក្ដីដឹងរលឹកបាន ដល់ខន្ធដែលអាស្រ័យនៅពីមុន, ឬពោលថា រលឹកជាតិទីបំផុតរបស់ខ្លួនបាន ៗ ក្នុងយាមទីពីរកើត “ចុតុបបាតញាណ” ប្រែថា សេចក្ដីដឹងចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ គឺការដឹងនូវសត្វទាំងឡាយល្អនិងអាក្រក់ផ្សេងគ្នាដោយអំណាចនៃកម្ម ឬន័យមួយទៀតហៅថា “ទិព្វចក្ខុ” ប្រែថា សេចក្ដីដឹងដូចជាដួងទិព្វ ៗ ក្នុងយាមទី ៣” “អាសវក្ខយញាណ” ប្រែថា សេចក្ដីដឹងនូវហេតុជាទីអស់ទៅនៃអាសវៈ គឺគ្រឿងសៅហ្មងដ៏គ្រោតគ្រាតនៅក្នុងខន្ធសន្ដាន ៗ

អធិប្បាយថា កំណត់ដឹងនូវខន្ធព្រមទាំងអាការៈដោយសេចក្ដីដែលជាហេតុ–ផលជាប់ទាក់ទងដល់គ្នានិងគ្នា ហៅថា “បដិច្ចសមុប្បាទ” ជាទីប្រជុំចុះក្នុង “អរិយសច្ច” កាលបើព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ដឹងយល់ច្បាស់បែបនេះហើយ ចិត្តក៏ផុតចាកសេចក្ដីសៅហ្មងទាំងពួង មិនប្រកាន់មាំដោយឧបាទាន មិនខ្វល់ខ្វាយក្នុងលោកិយសុខដែលជាសុខមិនពិតប្រាកដ ហើយនិងជាសុខមិនប្រសើរថ្លៃថ្លា ៗ

## អរិយសច្ច

ធម៌ដ៏វិសេសដែលព្រះពុទ្ធជាម្ចាស់ត្រាស់ដឹង ហើយទ្រង់បានត្រាស់ប្រៀនប្រដៅបុគ្គលដទៃឲ្យត្រាស់ដឹងតាម ហៅថា អរិយសច្ច គឺសេចក្ដីពិតយ៉ាងខ្ពស់មាន ៤ ប្រការៈ

១- ទុក្ខ ប្រែថាសេចក្ដីលំបាក កើតដោយផ្លូវកាយ – ចិត្ត

២ - ទុក្ខសមុទយ ប្រែថា ហេតុកើតឡើងនៃសេចក្ដីទុក្ខ

៣ - ទុក្ខនិរោធ ប្រែថា សេចក្ដីរលត់ទុក្ខ

៤ - ទុក្ខនិរោធគាមិនីបដិបទា ផ្លូវជាដំណើរដល់នូវសេចក្ដីរលត់ទុក្ខ; ឬហៅដោយខ្លីថា “ទុក្ខ, សមុទយ, និរោធ, មគ្គ”;

សូមអធិប្បាយតាមលំអាននៃបឋមទេសនារបស់ព្រះពុទ្ធជាម្ចាស់ ដែលហៅថា «ធម្មចក្ក»; តែមុននឹងអធិប្បាយ សូមដកស្រង់យកចំពោះតែគោលសេចក្ដី ដែលសំដែងដោយចតុរារិយសច្ច មកសំដែងទុកក្នុងទីនេះដូចតទៅ៖

១–ទុក្ខអរិយសច្ច: ព្រះពុទ្ធជាម្ចាស់ទ្រង់បរិយាយថា: សេចក្ដីកើតក៏ជាទុក្ខ, សេចក្ដីចាស់ក៏ជាទុក្ខ, សេចក្ដីស្លាប់ក៏ជាទុក្ខ, សេចក្ដីសោកសង្រេងសង្រែ សេចក្ដីឈឺចាប់, សេចក្ដីខូចចិត្ត, សេចក្ដីចង្អៀតអង្អល់ចិត្តក៏ជាទុក្ខ, សេចក្ដីព្រាត់ប្រាសចាករបស់ដែលជាទីស្រឡាញ់ទាំងឡាយក៏ជាទុក្ខ, ប្រាថ្នារបស់ណា មិនបានរបស់នោះដូចសេចក្ដីប្រាថ្នាក៏ជាទុក្ខ បើពោលដោយខ្លីថា ឧបាទានក្ខន្ធទាំង៥ក៏ជាទុក្ខ ។

ពួកជនដោយច្រើន កាលបើពន្យល់របស់ជាទុក្ខឲ្យស្ដាប់ ក៏រមែងចូលចិត្តទាំងអស់ ។ វៀរលែងតែគោលសេចក្ដីថា: «សេចក្ដីកើតក៏ជាទុក្ខ» នេះនៅមានមនុស្សខ្លះឆ្ងល់, តែបើតាមពិតមិនគួរឆ្ងល់ឡើយ បើល្បងពិសោធន៍មើលឬត្រិះរិះមើលក៏អាចដឹងអាចយល់បានថាជាទុក្ខមែន៖

អាការដែលមនុស្សយើងប្រសូតចាកគភ៌មាតានោះឯង មិនមែនប្រសូតចេញបានដោយស្រួលទេ តែងមានសេចក្ដីលំបាកជាអនេកប្បការ; តែថាខ្លួនយើងចាំមិនបាននូវសេចក្ដីទុក្ខដែលបានទទួលក្នុងពេលនោះ ។

១, បើពោលឲ្យប្រណីតគួរគិតឲ្យល្អថា: បើយើងមិនបានកើតមកជាមុនទេ ក៏មិនត្រូវចាស់ មិនត្រូវឈឺ មិនត្រូវស្លាប់ មិនត្រូវជួបប្រទះអារម្មណ៍ផ្សេង ៗ ដែលធ្វើឲ្យកើតទុក្ខ, ការកើតនោះត្រាប់ទៅរកសេចក្ដីទុក្ខមួយយ៉ាង ដែលយើងត្រូវជួបប្រទះក្នុងជីវិត ។ កាលបើបានកើតមកហើយ ទើបកើតសេចក្ដីប្រកាន់មាំនឹងសេចក្ដីកន្ទល់ក្នុងបញ្ចក្ខន្ធ ដែលសុទ្ធតែជាសេចក្ដីទុក្ខទាំងអស់ ។ (នៅមានត)

# ដំណើរទស្សនា

(ត)

១ទី២–នៅលើចំនួនសន្លឹកឆ្នោតទាំងនោះ ជួនកាលមានលេខដែលត្រូវផ្ទៀង៥ខ្ទង់ ឬ ៦ ខ្ទង់តាមសេចក្ដីសំគ្រតរបស់កម្មការ ៗ នៅលើបណ្ណកម្មវិធី មានពាក្យសេចក្ដីយ៉ាងពិស្ដារអំពីចំនួនមុខរតដែលត្រូវបានទទឹងចំនួនទឹកប្រាក់តាំងតែពីរង្វាន់ទី១ដរាបទៅ ចំពោះសន្លឹកឆ្នោតណាដែលមានលេខតុល្យភាពដូចគ្នានឹងលេខចេញ, ទាំងមានប្រាប់ឈ្មោះវង់ល្មោនដែលគេទឹងជួលមកលេងក្នុងពិធីបុណ្យនោះផង ៗ

១ទី៣– លុះបានចាត់កម្មវិធីដូចដែលពោលមកខាងនេះហើយ ក្នុងថ្ងៃមុនថ្ងៃចូលបុណ្យចំនួនជាងកន្លះខែ គណៈកម្មការក៏ចាត់ជួលរថយន្តមួយយ៉ាងធំល្មមមក ហើយតុបតែងដោយគ្រឿងអលង្ការផ្សេង ៗ មានបងសំពត់ផ្ទាំងអក្សរដែលរចនាយ៉ាងល្អហើយធំ ៗ ច្បាស់ ៗ ជាការប្រកាសប្រាប់នូវពិធីបុណ្យនឹងស្ថានទីដែលត្រូវធ្វើជាដើម, ម្យ៉ាងទៀតនៅលើរថយន្តនោះ មានចាក់ថាសម៉ាស៊ីនច្រៀងដែលបញ្ចេញតាមបំពង់បញ្ចេញសម្លេង (ឧគ្ឃោសនៈស័ព្ទ) ដែលគេប្រដាប់លើដំបូលរថយន្ត ៗ ពេលនោះគណៈកម្មការចំនួន ៥-៦ នាក់តែងខ្លួនយ៉ាងស្អាតបាតតាមបែបស៊ីវិល័យរបស់ជនជាតិក្ខមា ដែលនៅទីងសំលៀកបំពាក់នោះ ៗ មានខ្ទាស់ប័ត្រសំគាល់ខ្លួនថាជាគណៈកម្មកាបុណ្យពិត ៗ កាន់ផ្ដិលប្រាក់ធំ ៗ ដែលនៅក្នុងផ្ដិលនោះ ៗ មានសន្លឹកឆ្នោតនឹងបណ្ណកម្មវិធីផងឡើងកាន់រថយន្តហើយឲ្យបរចេញទៅកាន់ទីគ្រប់ច្រកល្ហក ៗ ក្នុងទីនោះ ៗ គេឈប់

បន្ទន់រវាង១០ ឬ ១៥នាទី ដើម្បីដើរលក់ឆ្នោតនឹងចែកកម្មវិធីបុណ្យ; ឯសម្លេងចម្រៀងដែលលាន់ចេញតាមទេគ្យាសនៈស័ព្ទ ក៏បេះតែឮសូរស័ព្ទអឺងកងមិនមានអាក់ ទោះរថយន្តបរក្តី ឈប់ក្តី វៀរលែងតែពេលណាដែលគេត្រូវប្រកាសឃោសនាប៉ុណ្ណោះ ៗ ការដើរឃោសនាបែបនេះ មានធ្វើតែពល់ ៗ ថ្ងៃដរាបទាល់តែអស់សន្លឹកឆ្នោត ៗ តាមធម្មតា ការផ្សៀងឆ្នោតនោះ ច្រើនតែធ្វើនៅថ្ងៃទីបំផុតបុណ្យ ៗ

១ទី៤— នាកាលដល់ថ្ងៃចូលបុណ្យហើយ គេក៏ប្រដាប់តាក់តែងទ្វារព្រះចេតិយឬពុទ្ធនាគានោះ ៗ ដោយភ្លើងអគ្គិសនីនឹងគ្រឿងភ្ញីផ្សេង ៗ គួរជាទីរមណីយទស្សនីយ៍; ឯវង់ល្ខោនដែលគេបានជួលកំណត់ទុកពីពេលមុន ក៏មកលេងក្នុងពេលនោះ, ចាប់បើកឆាកលេងតាំងពីម៉ោង៩យប់ដល់ម៉ោង៧ព្រឹក គំរប់៣យប់ឬលើសពីនោះតាមកម្មវិធី ៗ ឯពេងល្ខោនជាភារៈលើអ្នកម្ចាស់បុណ្យ ៗ ចំណែកអ្នកដែលមកមើលល្ខោននោះសុទ្ធតែមកប្រកាន់ទីកន្លែង កន្លែងបោះបង្គោលដីសរសេរឈ្មោះទុកជាមុន៣-៤ថ្ងៃ ៗ ក្នុងរាត្រីដែលល្ខោនផ្តើមលេងអ្នកទាំងនោះ ខ្ចះកាន់កន្ទេលខ្នើយ នាំកូនចៅមកដេកមើលក្នុងទីនោះតែម្តង ៗ តែថា ការរាស់ដីប្រកាន់កន្លែងមើលល្ខោននេះ មិនមានត្រូវបង់ខាតសោហ៊ុយទេ, ទាំងការលក់ដូរផ្សេង ៗ ក្នុងទីបុណ្យ ដែលពិនិត្យមើលទៅឃើញសុទ្ធតែជនជាតិកូមាលក់ដូរនោះ ក៏មិនមានត្រូវបង់ពន្ធអាករឡើយ ដោយអ្នកទាំងនោះសុទ្ធតែបានទិញសន្លឹកឆ្នោតហើយស្រេច ៗ វេលាថ្ងៃក្នុងពិធីបុណ្យនោះ មិនឃើញមានបាត់ការធ្វើអ្វីទេ ស្ងាត់ឈឹងដូចថ្ងៃធម្មតា ៗ

(នៅមានត)

# ប្រវត្តិសង្ខេបនៃនាលន្ទា (តនិងចប់)

បំណែកប្រទេសជប៉ុននិងទីបេត៍ ក៏បានបញ្ជូនព្រះត្រៃបិដកខាងលទ្ធិមហាយាន និងគម្ពីរផ្សេងៗ ជាភាសាជប៉ុននិងទីបេត៍ ។ ក្រៅពីនេះ សហរដ្ឋអាមេរិកបានជួយប្រាក់ ១ ម៉ឺនដុល្លា ដើម្បីទិញសៀវភៅសម្រាប់តម្កល់ទុកក្នុងបណ្ណាល័យនៃវិជ្ជាស្ថាននេះ ។ ប្រទេសទាំងអម្បាលនេះ បានបញ្ជូនសៀវភៅខាងវិទ្យាសាស្ត្រដំពូកខ្លះ ដូចយ៉ាងតក្កវិជ្ជា (logic) ទស្សនវិជ្ជា (Philoophy) និងនិរុត្តិសាស្ត្រ (Philology) ជាដើម ។ ឯក្បួនច្បាប់ប្រៀបធៀបសាសនាផ្សេងៗ គណកម្មការវិជ្ជាស្ថាននេះបានចាត់ចែងឡើងខ្លះ ។

ឯពួកនិស្សិតដែលរៀននៅវិជ្ជាស្ថាននេះ ផ្នែកបព្វជិតគេឲ្យនៅក្នុងគ្រឹស្ថានសិក្សាធំ, ផ្នែកគ្រហស្ថឲ្យនៅក្នុងសណ្ឋាគារសម្រាប់វិជ្ជាស្ថាន ។ រាជការបានជួលសណ្ឋាគារមួយធំមានជាន់ពីរថែមទៀត សម្រាប់ជាលំនៅរបស់និស្សិតដែរ ។ រាជការទើបនឹងសាងហើយស្រេចនូវគ្រឹស្ថាន ៤ ខ្នង សម្រាប់ចាងហ្វាងនិងសាស្ត្រាចារ្យ ។ សព្វថ្ងៃគេកំពុងចាត់ការឲ្យសាងគ្រឹស្ថានសិក្សាមួយខ្នងទៀត ប្រហែលជាធំជាងគ្រឹស្ថានសិក្សាមុនៗ តាមគ្រោងការដែលគេបានគិតទុកជាស្រេច និងដោយជំនួយអំពីរដ្ឋាភិបាលយ៉ាងពេញបន្ទុកនោះ, គេបំរុងនឹងពង្រីកវិជ្ជាស្ថាននាលន្ទានេះឲ្យបានជាមហាវិទ្យាល័យពេញលក្ខណៈក្នុងអនាគតឆាប់ៗនេះ ។

## អំពីថ្នាក់រៀន

តាមលក្ខន្តិកដែលទើបនឹងចេញប្រើថ្មីៗនេះ ថ្នាក់រៀន ៤ ឆ្នាំ គឺ:

ឆ្នាំទី ១– ថ្នាក់សាស្ត្រី (Shastry) សម្រាប់និស្សិតដែលចេះបាលីតិច,

ថ្នាក់ទី ២– ថ្នាក់បាលីអាចារ្យ (Achaya closs) សម្រាប់និស្សិតដែលចេះបាលីគ្រាន់បើ,

ថ្នាក់ទី ៣– បរិញ្ញាត្រី (B.A.: Bachelor of Arto) វិជ្ជាគ្រប់យ៉ាងរៀនជាភាសាអង់គ្លេសទាំងអស់,

ថ្នាក់ទី ៤– ថ្នាក់បរិញ្ញាទោ (M.A.: Master of Arts) បាលីនឹងអង់គ្លេសបញ្ចូលគ្នា ។

ឯភាសាឯទៀតដែលមានរៀនក្នុងវិជ្ជាស្ថាននេះគឺ សំស្ក្រឹត, ហិណ្ឌី, បារាំង, ចិន, ជប៉ុន, ទីនឹងទីបេត៍, ប៉ុន្តែភាសាទាំងនេះបើពុំរៀនក៏បាន ។ ភាសាដែលត្រូវតែរៀនខានពុំបាន គឺ បាលីនឹងអង់គ្លេស ។ បាលីប្រើសម្រាប់ស្រាវជ្រាវច្បាប់ព្រះពុទ្ធសាសនាពិតៗ មានអភិធម្មជាដើមនឹងក្នុងការសរសេរប្រឡង ។ អង់គ្លេសប្រើជាភាសាកណ្ដាល សម្រាប់ពន្យល់ក្នុងវិជ្ជាផ្សេងៗ នឹងក្នុងការប្រឡង ។

និស្សិតដែលនៅរៀនសព្វថ្ងៃ ពុំទាន់មានច្រើនប៉ុន្មានទេ, រួមទាំងអស់ចំនួន ៥០ រូបប៉ុណ្ណោះ ។ បណ្ដានិស្សិតទាំងនោះ សមណនិស្សិតមាន ២០ រូបគឺ: មកពីលង្កាទ្វីប ៨ រូប. សៀម ១១, ខ្មែរ ៣, យួន ១, ឥណ្ឌៀ ១ ។ សមណនិស្សិតលាវនឹងមក ២ រូបទៀតក្នុងពេលឆាប់ៗ នេះ; សមណនិស្សិតសៀមចេះតែមានមកបន្តៗ គ្នាជាលំដាប់ៗ ក្រៅអំពីនេះសុទ្ធតែគ្រហស្ថហើយច្រើនតែជាតិឥណ្ឌៀ ។ មានតែ ៣ រូបដែលជាជនបរទេស គឺជាតិទីបេត៍ ១ រូប, ជប៉ុន ២ រូប ។

សេចក្ដីពិសេស:

---

រដ្ឋាភិបាលថៃ ដោយសម្ដីងឃើញអនាគតមហាវិទ្យាល័យនាលន្ទា, បានអនុមតិឲ្យទិញដីមួយកន្លែងប្រហែល ១០០ម, ៤ ជ្រុង ជិតវិជ្ជាស្ថាននាលន្ទា ដើម្បីកសាងវត្ត

សម្រាប់ឲ្យភិក្ខុ-សាមណេរជាតិថៃនៅសំណាក់អាស្រ័យសិក្សា ។

ថ្ងៃទី ១៩ មករា ព.ស. ២៤៩៩ គ.ស. ១៩៥៦

សមណនិស្សិតខ្មែរ

នៅវិជ្ជាស្ថាននាលន្ទា ប្រទេសឥណ្ឌា



ពុទ្ធប្បវត្តិ (គ)

ពិធីច្រត់ព្រះនង្គ័ល

ពិធីរៀបក្បួនស្រែ តាមក្រសែច្រតនង្គ័ល ព្រះបិតាខ្វាយខ្វល់ ស្ទំរវល់ហែក្សត្រា ។

នាហ្មឺនមុខមន្ត្រី ព្រមសេនីយ៍នឹងសេនា ស្រីឆ្គារជាបរិវារ ចរយាត្រាទីស្រែហោង ៗ ដល់ហើយព្រះបិតា រៀបអាសនាដោយហ្មត់ហ្មង ស្រីស្នំអក់យាយផង តាំងផ្គូរផ្គង រាជបុត្រា ៗ ឲ្យផ្ទុំនាខាងក្រោម ដើមព្រីងស្មោមស្ទុកសាខា ស្រីស្នំគាល់គ្រៀបគ្រា ថែរក្សាជាគំនាល់ ៗ ឯអស់ស្រីបរិវារ ចិត្តប្រាថ្នាចង់ឲ្យស្គាល់ មើលប្រត់ព្រះនង្គ័ល មិននៅសល់ទាំងអស់គ្នា ៗ ឯអង្គពោធិសត្វ យល់ឃើញស្ងាត់ចាកនិទ្រា ទ្រង់គង់វង់ ធម្មា លើអាសនានៅវិមាន ៗ ស្រីស្នំបូលវិតាំង ត្រឡប់គេចមកបំពោះ ឃើញអង្គ ព្រះទ្រង់យស តែនព្រះបាទល្អថ្កើងថ្កាន ៗ កំពុងទ្រង់ភាវនា អនុស្សតិដាក់កម្មដ្ឋាន បិតាជ្រាបដើមដាន មកសំពះព្រះអយ្យបុត្រ ៗ សរសើរព្រះបារមី ដោយសេចក្តី អស្ចារ្យផុត គឺអង្គអនាគត ខ្ពស់បំផុតលើលោកា ៗ ឯម្លប់ដម្លូព្រឹក មានសន្ទឹកមែក សាខា ព្រះអាទិត្យជ្រេសុរិយា ឯឆាយាពុំជ្រេឡើយ ៗ ឯអស់ព្រៃព្រឹក្សា មានឆាយា ឥតល្ហៃល្ហើយ ពុំបែរទៅតាមឡើយ នៅកន្តើយតាមធម្មតា ៗ ដោយហេតុបុណ្យ បារមី ព្រះពោធិ-សត្វអស្ចារ្យ ឯអង្គព្រះបិតា នាំបុត្រាចូលវាំងស្ថាន ៗ

## កាលព្រះពោធិសត្វចេះយាត្រា

លុះបានចេះយានដល់ ត្រាពុំឃ្លាយូរប៉ុន្មាន ដោយបុណ្យថ្លៃថ្កើងថ្កាន ពុំរំខាន ពីហេតុអ្វី ៗ កក្រ្តាស្រស់ញញឹម គ្មានអ្វីផ្ទឹមលោកទាំងបី អស្ចារ្យផ្ទៃកពេកក្រៃ នឹង រកអ្វីប្រៀបពុំបាន ៗ ថ្ងៃមួយពោធិសត្វ ទ្រង់យានថ្វាត់ដោយក្សេមក្សាន្ត យានចូល ឆ្ពោះទៅស្ថាន ហោព្រះរូបសប់ព្រះទ័យ ៗ

លុះយានចូលទៅដល់ រូបដំកល់ក្នុងហោត្រៃ កិលចុះមកដល់ដី ក្រាបទៀបនៃ ព្រះបាទា ៗ ហើយអង្គពោធិសត្វ ទ្រង់យានថ្វាត់ដល់មាត់ទ្វារ គិតក្នុងព្រះទ័យា សំពះ

រូបនាងទេវី ។ លុះទ្រង់យានទៅដល់ រូបដំកល់ចុះម្នាម្នី សុះមកថ្វាយវន្ទ័យ ពង្សពោធិទៀបព្រះបាទ ។ គួរឲ្យនឹកអស្ចារ្យ បារមីតាព្រះនរនាថ កសាងអន្លើនជាតិ ពុំមានឃ្លាតលុះកិសម័យ ។

## ពួកស្តេចសាក្យថ្វាយខ្សែក

ថ្ងៃមួយពួកសាក្យ ចិត្តស្មោះស្ម័គ្រពន់ពេកក្រៃ យកខ្សែពេជ្រល្អថ្លៃ មកថ្វាយនៃព្រះសិទ្ធត្ថ ។ ឯខ្សែពេជ្រសិរី ចាំងរស្មីលើសមកិត ធ្លុះពីអង្គសិទ្ធត្ថ ដូចនព្វរត្នកែវសូរ្យកាន ។ អស់ពួកពជសាក្យ អុរអន់គ្បូតធ្មឹមបាន សរសើរគ្រប់ៗប្រាណ ថាដោយមានបារមីក្រៃ ។

## ទេវតានិម្មិតស្រះថ្វាយ

លុះព្រះរាជកុមារ មានជន្មាប្រាំពីរនៃ បិតាក្អកព្រះទ័យ គិតកែខែជីកស្រះថ្វាយ ។ ដើម្បីរាជកុមារ ស្រង់កាយាតាមសប្បាយ កុំឲ្យមាននឿយណាយ លំបាកកាយរាជបុត្រា ។ ស្រាប់តែក្តៅទៅដល់ ទីមណ្ឌលផែនសិលា គឺជាទីអាសនា ព្រះឥន្ទ្រានាសួគិស្ថាន ។ កោសិយជ្រាបហេតុសព្វ ទ្រង់បង្គាប់ពុំហ៊ានខាន វិស្សកម្មដាងចំណាននិម្មិតបានស្រះហើយនៃ ។ ប្រញាប់ឆាប់បំផុត ជាបំហុតរហ័សក្រៃ ដូចមនុស្សខ្ទាំងលាដៃ ហើយបត់ដៃនោះឯងណា ។ រួចក៏ថ្វាយបង្គំ លាឥន្ទ្រធំជាងទេវតា ចុះដល់ដីកាលណា ស្រះបោក្ខាទឹកថ្លាពេញ ។ ត្រដាក់គួរចាប់ចិត្ត ចង់ស្នេហ៍ស្និទ្ធគ្មានលំគេញ លំចង់ឈូកដុះពេញ តាំងបញ្ចេញផ្កាព្រោងព្រាត ។ ព្រលិតកំពីងពួយ លូតលាស់ត្រួយដោយគគាត ឧប្បលបទ្មជជាតិ ពុំរវាតដុះត្រៀបត្រា ។ អង្គព្រះពោធិសត្វ ស្នំប្រើនក្តាត់តែងលីលា ហែមកស្រង់គង្គា រាល់ទិវាជាប្រក្រតី ។

## ព្រះបិតាសាងប្រាសាទបីថ្វាយ

លុះដល់ព្រះជន្មា សោឡសារូបពិសី ទើបក្សត្រនរបតី ទំហ្នុតខ្នីសាងប្រាសាទ ៗ ប្រាសាទបីតម្រូវ តាមរដូវល្អដល់ខ្នាត ទីមួយជាន់ប្រាំស្អាត លើសប្រាសាទលើប្រថពី ៗ សម្រាប់រដូវក្តៅ គ្មានអ្វីទៅទីងយាយី សុខសាន្តគ្រប់នាទី សោយសោភីក្សាន្តកិរម្យ ៗ ប្រាសាទមួយទៀតណា ល្អថ្ងៃថ្លាខ្ពស់ស្កុកស្កុក ប្រាំពីរជាន់ស័ក្តិសម គួរអភិរម្យរដូវភ្លៀង ៗ ប្រាសាទមួយនោះឯង ខ្ពស់លើសលែងដោយទាត់ទៀង ប្រាំបួនជាន់ឥតឃ្លៀង គង់ពល់រៀងរដូវល្ងា ៗ គង់នៅប្រាសាទមួយ ឥតមានព្រួយបួនខែណា ក្សេម-ក្សាន្តព្រះទ័យា ពល់ទិវាក្សាន្តសប្បាយ ៗ

## ព្រះបិតាទ្រង់ប្រគល់រាជ្យឲ្យព្រះសិទ្ធត្ថ

អង្គព្រះវរបិតា ទ្រង់បញ្ជាក្សត្រទាំងឡាយ ដែលជាប់វង្សគ្រប់កាយ យកមកថ្វាយនូវបុត្រី ៗ ដែលមានរូបស័ក្តិសម រាងរៀវក្តីធ្ងើមហេសី ដ្បិតព្រះនរបតី សប់ព្រះទ័យថ្វាយរាជ្យរដ្ឋ ៗ ឲ្យដល់ព្រះរាជបុត្រ ល្អបរិសុទ្ធនាម "សិទ្ធត្ថ" ឲ្យគ្រប់គ្រងរាស្ត្ររដ្ឋ ជាកំណត់តនៅណា ៗ ឯព្រះញាតិវង្ស ជាតួដតង់វត្តិយា ប្រកែកហើយពោលថា រាជបុត្រាល្អរូបក្រៃ ៗ សមធ្វើជាក្សត្រពិត វេទ,មន្តវិទ្ធិសិល្បស័យ ពុំទាន់បេះឡើយនៃ ធ្នូជាញស័យក៏ពុំមាន ៗ បើមានសង្គ្រាមសឹក កើតវឹកកូងរាជស្ថាន ពុំអាចតតាំងបាន ពុំអាចហ៊ានច្បាំងឡើយណា ៗ នឹងកើតកលិយុគធំ ក្នុងបវរមរាជស្រមា វិនាសរាស្ត្ររដ្ឋា សន្តិសុខាពុំមានឡើយ ៗ

(នៅមានត)

# ស្ថានការណ៍នៃសហភាពភូមា (ត)

៤ ការគោរពបូជនីយដ្ឋាន – ប្រជាជននៅសហភាពភូមា មានការគោរពបូជនីយដ្ឋានជាត្រីមុខ មានការធ្វើដំណើរទៅទស្សនាការ នូវបូជនីយដ្ឋានជាទីតាំង មានការគោរពបូជានមស្ការព្រះស្តូបព្រះចេតីយ៍ ព្រះបដិមាករផ្សេង ៗ ដែលប្រតិស្ឋានត្រង់កន្លែងផ្សេង ៗ ជាប្រធាន ប្រហែលគ្នានឹងពលរដ្ឋនៃប្រទេសខ្លះ ៗ ដែលគាប់ចិត្តគាប់អធ្យាស្រ័យទៅគោរពបូជាកន្លែងស៊ីផឹក កន្លែងរាំរង់ កន្លែងលេងល្ខោន កុន អាយ៉ៃ ដែរ ៗ កិច្ច-វត្តបែបនេះ មានជាសាធារណ៍ទូទៅស្ទើរតែគ្រប់មនុស្ស គ្រប់វ័យគ្រប់ភេទនឹងគ្រប់ឋានៈ មិនថាជាប្រុស ឬស្រី ចាស់ ក្មេង កំលោះ ក្រមុំ គ្រហស្ថបព្វជិត មន្ត្រីរាស្ត្រឡើយ គឺទូទៅទាំងអស់ ៗ ចុះនៅប្រទេសកម្ពុជាយើងមានបូជនីយដ្ឋាន សម្រាប់គោរពបូជានមស្ការដូចជាប្រទេសគេដែរឬ? ឆ្លើយថា មាន, តែជាតិចស្តួចស្តើងពេកណាស់ គួរយ៉ាងដូចជា ព្រះវិហារព្រះកែវមរកត ដែលជាព្រះហស្តរបស់ព្រះបាទសម្តេចព្រះនរោត្តម ( អតីតព្រះបរមរាជាធិរាជ ) ព្រះអង្គទ្រង់សាងទុកជាទីគោរពបូជានមស្ការ នឹងជាទី-អនុស្សាវរីយ៍នៃពលរដ្ឋខ្មែរទាំងប្រទេស គួរតាំងទុកជាបូជនីយដ្ឋានដ៏ឧត្តម ១ កន្លែងដែរ ទាំងបូជនីយដ្ឋានឯទៀត ៗ ដែលប្រតិស្ឋាននៅក្បែរព្រះវិហារនេះក៏មាន, តែពុំសូវមានមនុស្សម្នាមហាជនសញ្ចរទៅមកគោរពនមស្កា បានដោយស្រួលសោះ អ្នកដែលបានទៅទស្សនាម្តង ៗ គឺគ្រាន់តែទៅមើលលេងមែន ៗ ពុំបានគិតថា « ឱ! កន្លែងនេះជាបូជនីយស្ថានដ៏មហាស្ចារ្យទេតើ គួរអញគោរពបូជា ដោយទេយ្យទានខ្លះ ៗ មានផ្កាភ្ញីទៀនធូប ឬកំរងផ្កាផ្សេង ៗ ដ៏ហោចទៅគ្រាន់តែដើរចូលទៅជិតងាកកន្ទុយភ្នែកក្រឡេកមើលដោយមនសិការ: នឹងស្វាមីភក្តិក៏ពុំសូវមាន កុំបាច់ពោលដល់ការគោរពបូជាដ៏ជាក់ស្តែងឡើយ ៗ

៣– ការអស្ចារ្យ ១ ផ្នែកទៀត  គឺប្រជាជនភូមាភាគច្រើនពេញចិត្តនឹងកិច្ចវត្ត គឺការធ្វើដំណើរពីស្រុកនិគមជនបទនីមួយ ៗ ឆ្ពោះទៅកាន់ស្រុកនិគមជនបទនីមួយ ៗ ដោយរថយន្តផ្សេង ៗ មានណែនាំបបួលបញ្ចុះបញ្ចូល បុត្រធីតា  សាលោហិត ឲ្យទៅគោរពនមស្ការបូជាបូជនីយដ្ឋានផ្សេង ៗ ឥតបើគិតដល់ការនឿយហត់ ការលំបាកលំបិន ការបង់ខាតប្រាក់កាសឡើយ  ការដែលធ្វើដំណើរទៅកាន់កន្លែងទាំងនោះទៀតសោត បើទីកន្លែងនោះតាំងនៅជិត ៗ ឬឆ្ងាយល្មម  គេត្រូវប្រដាប់ស្បៀងអាហារដោយបាន ស្រាក់ ១ ស្រាក់ ៗ ទៅតាមខ្លួនផង  បើទីនោះតាំងនៅឆ្ងាយ ( ដេកផ្លូវ ) ត្រូវដាក់ឆ្នាំង-ឆុស-អង្ករ ព្រមទាំងគ្រឿងផ្សំអាហារផ្សេង ៗ ទៅតាមផង ដើម្បីកុំឲ្យបង់ខាតប្រាក់កាស ទិញដូរពីអ្នកលក់  ព្រោះករណីយកិច្ចនេះជាការឆ្ងាយ ហើយអាចធ្វើខ្លួនឯងកេតដោយ ឥតលំបាកឡើយ ៗ ព្រោះប្រជាជនគេគិតថា របស់ណាដែលខ្លួនឯងធ្វើបាន មិនចាំបាច់ ទិញដូរអំពីអ្នកដទៃទេ  បើទុកជារបស់នោះល្អក្ដី កណ្ដាលក្ដីក៏ជារបស់ឯង-ជាតិឯងធ្វើ ស្រាប់ ៗ  ប្រជាជនភូមាភាគច្រើនមិនសូវចូលចិត្ត បរិភោគអាហារដោយផ្សារផ្សាទេ ដោយគេគិតថា ការនៅទទួលទានភោជនីយាហារក្ដី ខាទនីយាហារក្ដីតាមហាងតូច-ធំ ឯផ្សារ ជាហេតុនាំឲ្យបង់ខាតសោហ៊ុយលុយកាក់ច្រើន ហើយពុំគ្រប់គ្រាន់ល្មមដល់ក្រុមគ្រួសារទៀតផង,  ឧបមាដូចជាក្នុងគ្រួសារមួយមានមនុស្ស ១២ នាក់, បណ្ដាមនុស្ស ទាំងអស់នោះ  ត្រូវបានទៅទទួលទានតែ ៦.៧ នាក់ប៉ុណ្ណោះក្រៅពីនោះពុំបានទៅ ៗ អ្នកដែលសល់នៅឯគេហស្ថាន ត្រូវបង់ខាតប្រាក់កាសដើម្បីភោជនាហារទៀត, ចុះបើ បំណាយប្រាក់កាសទិញភស្តុភារទាំងនោះ  យកមកចំអិនបរិភោគឯគេហស្ថានរបស់ខ្លួន ហើយបរិភោគទៅវិញ  បានល្មមគ្រាន់គ្រប់គ្នាហើយជាការឆ្ងាយថែមទាំងឆ្ងាញ់ពិសា ទៀតផង ៗ  (នៅមានត)




ថ្ងៃអង្គារទី ២២ កុម្ភៈ ព. ស. ២៤៩៨

ភិក្ខុ ហុក-សៀក និស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ សូមបំរើនពរមកលោកបណ្ណាធិការ ទស្សនាវដ្ដី ពុទ្ធិកវិទ្យាល័យ

សូមជ្រាប ។

ដ្បិតអាត្មាភាពបានទទួលភារៈជាអ្នកនិពន្ធឥតបង់ អំពាវនាវ សូមឲ្យលោកបណ្ណាធិការ ទស្សនាវដ្ដីនេះ, ក្រុមជំនុំប្រែព្រះត្រៃបិដក និងលោកអ្នកមានបញ្ញាឆ្លៀវឆ្លាសក្នុងច្បាប់ពុទ្ធសាសនាទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា សូមឲ្យជួយវិនិច្ឆ័យសេចក្ដីងឿងឆ្ងល់ ដូចលោកបានចុះក្នុងទស្សនាវដ្ដីលេខ ៧ ទំព័រ ២៣ គ.ស. ១៩៥៥ រួចម្ដងហើយ ទស្សនាវដ្ដីនេះ បានឆ្លើយតបថា ចាំដល់លេខខាងមុខនឹងជូនសេចក្ដីពិត ។ ពុទ្ធបរិស័ទស្រុកស្អឹងត្រង់ បេះតែទន្ទឹងចាំមើលសេចក្ដីពិត នឹងអាលបានប្រតិបត្តិតទៅ ។

តមកទៀតបានទទួលទស្សនាវដ្ដីលេខ ៩-១០, បរិស័ទទាំងឡាយ មានសេចក្ដីត្រេកអរជាទីបំផុត ដោយសារបានឃើញអត្ថបទមួយមាននាមថា លិខិតបណ្ណាធិការ គិតស្មានថានឹងបានទទួលសេចក្ដីពិត ក្នុងភាគទី ២ នេះជាមិនខាន តែដល់អានបានបន្ដិចទៅ. ឃើញមានសេចក្ដីថា "ខ្ញុំអាចវិនិច្ឆ័យរឿងនេះបាន" ។ តែមុននឹងវិនិច្ឆ័យបញ្ហានេះ គួរតែយកបញ្ហាយ៉ាងស្រាលមួយសួរចំពោះជនអ្នកប្រតិបត្តិតាមគោលការណ៍ទាំងពីរបែបនេះសិន ដើម្បីជាការត្រិះរិះតទៅអនាគត ។ ឃើញថាបញ្ហានេះ ធ្លាក់លើម្ចាស់ដើមវិញ, សូមជំរាបថា ពុទ្ធបរិស័ទស្រុកស៊ុយគ្រង់ មិនសូវខ្វាតវៀងវៃទេ ព្រោះមិនសូវបានទទួលការសិក្សាឲ្យបានម៉ត់ចត់ មានតែលោកអ្នកប្រាជ្ញនៅទីក្រុងនឹងហើយទើបប្រសប់ប៉ិនប៉ាវ ក្នុងការដោះស្រាយធម៌អាថ៌ផ្សេងៗ; តែក្នុងពេលនេះ បើលោកតម្រូវឲ្យយើងខ្ញុំដោះស្រាយបញ្ហានេះ យើងខ្ញុំសូមដោះស្រាយតាមបន្ទាល់!

លោកបណ្ណាធិការសួរថា "ជាយូរណាស់មកហើយ បញ្ហាបែបនេះម្ដេចក៏មិនលេចឮឡើងក្នុងដែនពុទ្ធជន?

ឆ្លើយថា: ក្រែងពុទ្ធជន មើលច្បាប់ពុទ្ធសាសន៍មិនទាន់គ្រប់គ្រាន់ ព្រោះច្បាប់មានច្រើន យើងមើលតែខាងដើមៗ ខាងចុងមិនទាន់បានមើល សូមលៃលកថែកមុខគ្នាមើលឲ្យគ្រប់ទៅមើល? យើងខ្ញុំក៏មិនដែលបានទទួលបញ្ហាបែបនេះដែរ ទើបតែក្នុងសម័យឯករាជ្យនេះ យើងខ្ញុំបានស្ដាប់អំពីសំណាក់ព្រះតេជគុណធម្មាចារ្យព្រះនាម ងាន លោកជាអ្នកស្ងប់ស្ងាត់ត្រេកអរតែក្នុងសេនាសនៈតាំងនៅក្នុងព្រៃ ប្រព្រឹត្តធុតង្គវត្តជានិច្ចៗ

សួរ — ព្រះសង្ឃក្នុងព្រះពុទ្ធសាសនាមានច្បាប់ហាមឃាត់មិនឲ្យពុទ្ធជនទទួលទានអំពីព្រះសង្ឃដែរឬទេ? បើមានតើគម្ពីរណា? មានអដ្ឋកថាដូចម្ដេច? មានបញ្ញត្ត

នៅទីណា? បំពោះហេតុដូចម្ដេច?

ឆ្លើយ-មាន! មានហាមមិនឲ្យឧបាសក-សិកា ទទួលទាន ឬ បរិភោគប្រើប្រាស់បច្ច័យរបស់សង្ឃទេ ព្រោះបរិភោគទាំង ៤ ព្រះពុទ្ធមិនមែនអនុញ្ញាតឲ្យឧបាសក-សិកាទេ អនុញ្ញាតឲ្យតែភិក្ខុទេតើ, ។ វត្ថុសេសសល់ វត្ថុណាក៏សេសសល់ដែរ បើដូច្នេះឧបា-សក-សិកា ប្រើប្រាស់ស្បង់ចីពរសង្ឃសេសសល់បានដែរឬទេ?

មានក្នុងគម្ពីរអនាគតវង្ស នឹងធម្មទាយាទសូត្រ ។ បើកាត់តាមសទ្ធាទេយ្យវិបាកៈ នឹងសាធារណីយធម៌ទី៥ បាលីនឹងអដ្ឋកថាដែលមាននៅក្នុងមហាបរិនិព្វានសូត្រ ទីឃនិ-កាយធកសូត្រ មជ្ឈិមនិកាយៈ លទ្ធលាភោ អវិភត្តិភោគី សព្រហ្មចារីហិ សីលវន្ត-ហិ សាធារណភោគី ហោតិ ។ អដ្ឋកថាៈ សីលវន្តេហីតិ វចនតោ គិហីនំ លាភេនលាភំ ជតឹសនតា មុខេន នកាតព្វោ ។ ពីរប្រស្នាខាងក្រោម សូមមើលក្នុងគម្ពីរទាំងនោះនឹងឃើញមិនខាន ។

ក្នុងអនាគតវង្ស ពោលថា ជន៤ពួកមិនបានជួបនឹងព្រះសិអារមេត្រីៈ

១– បញ្ចានន្តរិយធម្មិកៈ, ២– អរិយុបវាទកៈ, ៣– មិច្ឆាទិដ្ឋិកៈ, ៤– សង្ឃកប្បិយ-ខាទកៈ ។ បណ្ដាធម៌ទាំង៤នេះ មានធម៌ទី៤ថា សង្ឃកប្បិយខាទកៈ អ្នកស៊ីវត្ថុរបស់សង្ឃមានទោស មិនបានជួបនឹងព្រះសិអារមេត្រី ត្រង់នេះសូមលោកជួយវិនិច្ឆ័យមើលៗ

ព្រះតេជៈគុណអាចារ្យបាន សំដែងថា ស៊ីមាន(១)ទោស, ស៊ីមិន(១)មានទោស, ឲ្យមាន(២)ទោស, ឲ្យមិនមាន(២)ទោស ។

ស៊ីមានទោសៈ ការស៊ីមានទោសនោះ មិនថាមុន-ក្រោយទេ ឲ្យតែស៊ីបេះតែមាន

(១) សំដៅគ្រហស្ថ, (២) សំដៅភិក្ខុ ។

ទោសទាំងអស់ ឲ្យតែសង្ឃមិនបានឲ្យ សង្ឃអ្នកឲ្យទៀតក៏មិនរួចពាក់អាបត្តិ ព្រោះគ្មានអនុញ្ញាត ។ កាកប្រេតទង់ញាតិព្រះបាទពិម្ពិសារាជ ជនទាំងនេះគេតែងនិយាយថា អ្នកនោះបាបព្រោះស៊ីមុន ។ អ្នកទាំងនោះស៊ីមុនគួរទេមានទោសស្រាលទេ ព្រោះថាវត្ថុនោះ ជារបស់ម្ចាស់ទានក៏ទេ, ព្រោះគេបំរុងនឹងឲ្យសង្ឃហើយ គេកាត់អាល័យហើយ ។ របស់នោះជាជារបស់សង្ឃក៏ទេព្រោះសង្ឃមិនទាន់បានទទួល ម្ដេចមានទោសដល់ម្ល៉េះ? បំណាច់បើសង្ឃបានទទួលទៀត តើមានទោសយ៉ាងណាទៅ?

ស៊ីមិនមានទោស ដូចជាវិឃាសាទ៥០០នាក់ ស៊ីស្ករ មច្ឆរិយសេដ្ឋីស៊ីនំអំបែង; ទាំងនេះសុទ្ធតែព្រះពុទ្ធបង្គាប់ឲ្យ ។

ឲ្យមិនមានទោស: ដូចរឿងសង្កិច្ចសាមណេរ ក្នុងធម្មបទអដ្ឋកថា, ឬឲ្យដល់មាតាបិតា, អ្នកមានពៀរ, ពួកចោរ, អ្នកដើរដំណើរដែលអស់ស្បៀងអាហារឥតមានញាតិមិត្រ ។ បើគ្មានហេតុដូចបង្ហាន់នាយបុន្ន ។ ទំនងជាសត្វស៊ីរបស់ដែលសង្ឃមិនបានឲ្យមានទោសហើយយ៉ាង បានជាស្ករក្លាយទៅជាថ្មក្ដៅ, នំអំបែងទៅជាភ្នំ, បង្ហាន់នាយបុន្ន បានត្រូវកប់ក្នុងដី ។

ក្នុងបបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ មានសេចក្ដីថា: ភិក្ខុសាមណេរ បំរើឧបជ្ឈាយាចារ្យ ប្រាថ្នាបាត្រ នឹងចីវរ ការបំរើក៏បាប បានបាត្រនឹងចីវរមកប្រើប្រាសក៏បាបទៀត ។ ឧបាសក-សិកា បំរើភិក្ខុសង្ឃប្រាថ្នាលាភ ក៏ដូចគ្នា ។

សេចក្ដីនេះ សូមលោកមើលតាមគម្ពីរដែលបានឆ្លើយហើយខាងលើនឹងក្នុងគម្ពីរដទៃទៀត ដើម្បីវិនិច្ឆ័យឲ្យច្បាស់លាស់ ទុកជាទិដ្ឋានុគតិ ដល់បច្ឆាជន មានយើងខ្ញុំ, ពុទ្ធបរិស័ទ ចំណុះវត្តគីរីវ័ន ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមជាដើម ។

ដោយយើងខ្ញុំមានសេចក្ដីសង្ឃឹមលើលោកបណ្ណាធិការ នឹងបណ្ឌិតជនជាតិយើង ជាមុខជានឹងសើរើកសេចក្ដីពិតនេះឲ្យឃើញជាមិនខាននោះ យើងខ្ញុំសូមបួងសួងចំពោះគុណព្រះត្រៃរត្ន នឹងពពួកទេវតាទាំងឡាយ សូមឲ្យជួយទ្រទ្រង់អាយុជីវិតទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យនេះ ឲ្យបានឋិតថេរចិរកាលរហូតគ្រប់ ៥០០០ ព្រះវស្សា ។

សូមទទួលសេចក្ដីរាប់អានយ៉ាងខ្ពស់អំពីសំណាក់នៃយើងខ្ញុំ

ហត្ថលេខា

ពុទ្ធបរិស័ទ ស្រុកស្ទឹងត្រង់

ចំពោះបញ្ហានេះខ្ញុំសូមអំពាវនាវដល់អ្នកប្រាជ្ញទូទៅក្នុងប្រទេសកម្ពុជា មេត្តាជួយឆ្លើយដោយអាងហេតុផលមកផង ហើយសូមឲ្យបានទាន់ក្នុងពេលឆាប់ ៗ ក្រែងលោមិត្តរួមសាសនាបានឃើញច្បាប់ក្បួនឯណាផ្សេងទៀតដែលគួរដល់ការដោះស្រាយ ព្រោះថាខ្ញុំនឹងសម្រេចឆ្លើយសេចក្ដីពិតជូនទៅលើទំព័រទស្សនាវដ្ដីយើងលេខ១៦ខាងមុខនេះ

សូមអរគុណទុកជាមុន

បណ្ណាធិការ

X

X X

វត្តទួលព្រះពន្លា នៅថ្ងៃទី៨ ខែមេសា ព.ស. ២៤៩៨ គ.ស. ១៩៥៦

ភិក្ខុ ចី-យឿង (អតីតធម្មាចារ្យ) វត្តទួលព្រះពន្លា ឃុំកណ្ដាលជ្រុំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

អាត្មាភាពសូមចំរើនពរបួលមកលោកចាងហ្វាងទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យ ភ្នំពេញ

សូមជ្រាប ។

អាត្មាភាពក្នុងនាមជាសមាជិក ដែលចុះឈ្មោះជាវទស្សនាវដ្ដីរបស់លោកប្រចាំឆ្នាំ ១៩៥៥-១៩៥៦ នេះ ។

អាត្មាភាពមានសេចក្ដីពេញចិត្តយ៉ាងក្រៃលែង ចំពោះអត្ថបទទាំងឡាយដែលនៅក្នុងផ្ទៃទស្សនាវដ្ដី ( គឺហាក់ដូចជាសាស្ត្រាចារ្យមួយ ) ដែលអាចបំពេញសភាពល្ងង់ខ្លៅរបស់អាត្មាឲ្យមានគំនិតភ្លឺថ្លាឡើងជានិច្ច នៅក្នុងពេលណាដែលចាប់អានឡើងម្ដង ៗ ។

ប៉ុន្តែនៅមានវិចិកិច្ឆា ( សង្ស័យ ) នឹងសៀវភៅក្បាលលេខ ១.២ ដែលមានឈ្មោះថា " ទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យ " ដោយហេតុថា ទស្សនាវដ្ដីពីរក្បាលនេះហាក់ដូចជាផ្សាយចេញសាធារណ៍ គ្មានកាលវេលានឹងកំណត់សោះ គឺពុំដឹងជាផ្សាយចេញនៅខែណា ក្នុងគ្រិស្តសករាជប៉ុន្មាន? គ្រាន់តែមានលេខប៉ុណ្ណោះ ) ឃើញថាផ្ទែកពីទស្សនាវដ្ដីមិត្តសាលាបាលីដែលផ្សាយចេញពីអតីតសម័យដោយពិត ។

ដូច្នេះអាត្មាភាពសូមចំរើនពរសួរលោកថា ៖

១- ទស្សនាវដ្ដីពុទ្ធិវិទ្យាល័យលេខ ១-២ ដែលផ្សាយចេញរួចហើយនោះ គេផ្សាយចេញនៅខែណា ? ក្នុងគ្រិស្តសករាជប៉ុន្មាន ?

២- តើយោបល់បែបម៉េច បានជាមិនសរសេរឈ្មោះខែដែលចេញ នឹងឆ្នាំដែលប្រចាំនៅខ្នងទស្សនាវដ្ដីដូចពេលមុន ? ឬក៏ការដែលចុះកាលបរិច្ឆេទនេះនាំឲ្យឥតប្រយោជន៍ ? សូមលោកវិសជ្ជនាទៅលេខក្រោយ ឲ្យអាត្មាភាពមានសមានចិត្តយល់ស្រប ទៅតាមយោបល់របស់លោកផង ?

ប៉ុន្តែបើតាមយោបល់របស់អាត្មាវិញ យល់ឃើញថា កាលបរិច្ឆេទ ( ថ្ងៃ - ខែ . ឆ្នាំ ) នេះ ជាការចាំបាច់របស់សាពត៌មានផ្សេង ៗ នឹងលះបង់ពុំបានឡើយ ឯយោបល់បែបនេះ ប្រហែលទួរទៅដល់ជនភាគច្រើន, ( ចំពោះមតិនៃអាត្មាភាព ) ។ ឬក៏លោកមិនដាក់ថ្ងៃ

ខែ-ឆ្នាំនេះដើម្បីឲ្យផ្សាយចេញ? ឆ្លើយយ៉ាងម៉េច ឆ្លើយយ៉ាងនេះថា បើទុកជាផ្សាយចេញនៅពេលណាក៏បាន ព្រោះគ្មានកំណត់ ថ្ងៃ ខែ ឆ្នាំ ។

ព្រោះថាទស្សនាវដ្ដីមុនៗ ឃើញមានជាគំរូស្រាប់មកហើយ អ្នកអានទាំងឡាយ មិនសូវសប្បាយចិត្តក្នុងការអានទេម៉េចក៏មិនសប្បាយ? បានជាមិនសប្បាយនោះ ព្រោះថា បើផ្សាយចេញនៅខែមករា, អ្នកអានត្រូវរង់ចាំអានទៅខែមិនា ឬមេសាឯណោះទៅ (ក៏ទន្ទឹងមើលផ្លូវហាក់ដូចជាទារក ដែលចាំផ្លូវម្ដាយទៅផ្សារ) ម្ល៉ោះហើយដំណឹងថ្មីៗ ក៏ក្លាយទៅជាដំណឹងចាស់អស់! បើយ៉ាងហ្នឹង តើឲ្យសប្បាយក្នុងការអានដូចម្ដេច?

ឱលោក! អាត្មាភាពដែលលើកសេចក្ដីសង្ស័យចំរើនពរជូនមកនេះ ពុំមែនដើម្បីជំទាស់ដល់យោបល់របស់លោកទេ គឺជាករណីមួយ ដែលគប្បីតែអាត្មាដោះស្រាយឲ្យអស់សេចក្ដីស្ទាក់ស្ទាញក្នុងចិត្ត; ពុំមែនលើកសេចក្ដីយល់ទាស់នេះ បំណងឲ្យលោកកែប្រែតាមយោបល់របស់អាត្មាក្នុងឋានៈជាឯកជននោះសោះឡើយ ។

មួយយ៉ាងទៀត ចំពោះរូបភាព (ទង់សាសនា, ជាដើម) ដែលនៅខាងខ្នងទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យលេខ ១-២ តើមនោធុរៈរបស់លោក បំរុងនឹងផ្ដិតដាក់តែរូបភាពមួយហ្នឹងជាដរាបតទៅ ឬ? ឬក៏មានបំណងកែប្រែទៀតដែរ? បើប្រសិនជាលោកពុំមានបំណងកែប្រែទៀតទេ, គឺធ្វើតែបែបនេះដរាបទៅ នោះអ្នកអានទាំងឡាយមុខជារិះគន់ថា: អ្នកនិពន្ធប្រហែលជាទាល់គំនិតក្នុងការរិះរករូបភាពហើយយ៉ាងមើទៅ! បានជាផ្ដិតដាក់តែរូបភាពដដែលៗ យ៉ាងហ្នឹង! ។

ចំពោះរូបភាពដែលលោកផ្ដិតដាក់លើខ្នងសៀវភៅលេខ ១-២ នោះឃើញថាជានិមិត្តរូបមួយ ដែលគួរឲ្យពេញចិត្តរបស់អ្នកពុទ្ធជនពន់ពេក, ប៉ុន្តែសូមលោកជ្រាបថា៖ ភោជនទាំងឡាយ ទោះបើមានឱជារសឆ្ងាញ់ពិសារបែបណាក៏ដោយ កាលណាបើ

បរិភោគដដែល ៗ ញយ ៗ ទៅអាចធ្វើអ្នកបរិភោគឲ្យនឿយណាយធុញទ្រាន់មិនខាន ៗ

ព្រោះហេតុនោះការផ្លាស់រូបភាពនៅខ្នងសៀវភៅ ទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យនេះ បើលោកមានឱកាសអាចធ្វើបាន សូមលោកប្រែឲ្យប្លែកគ្រប់ក្បាលទាំងអស់ ព្រោះថាការផ្លាស់រូបភាពពល់ក្បាលនេះ ជាស្នេហ៍មុខមួយ ដែលអាចធ្វើអ្នកអានមិនឲ្យរុញរាក ក្នុងការអាន; ឃើញថាជាអាហារមួយ សម្រាប់បំប៉នទារកទស្សនាវដ្ដីឲ្យមានកម្លាំង, នឹងជីវភាពប្រព្រឹត្តទៅអស់កាលជានិច្ច ៗ

អាត្មាភាពសូមសំដែងមនោសញ្ចេតនាដ៏បរិសុទ្ធ ចំពោះរូបលោក! អាត្មាមានសោមនស្សចេតនាជាតិយេភាព បើប្រសិនជាទស្សនាវដ្ដីនេះមានជីវភាពអនុវត្តទៅអស់កាលវែង ៗ

ព្រោះអាត្មាយល់ឃើញថា: មានតែទស្សនាវដ្ដីនេះមួយទេ ដែលមានមនោធម្ម: នឹងឧត្តមគតិ លើកស្ទួយនូវសាសនានឹងអក្សរសាស្ត្រឲ្យមានការរៀធម៌ស្មើនឹងការប្រទេសនានា ក្នុងពិភពលោក ៗ ដោយហេតុប៉ុណ្ណោះទើបអាត្មាភាពលើកសេចក្ដីយល់ទាស់បំរើនពរជូនមកនេះ ៗ

ចំពោះសេចក្ដីសង្ស័យនេះ បើលោកយល់ឃើញថា មានប្រយោជន៍ សូមលោកមេត្តាឆ្លើយតបដោយសុទ្ធចិត្ត, បើយល់ឃើញថាពុំមានប្រយោជន៍ទេ សូមបដិសេធចោលដោយឥតមានទោមនស្សឡើយ ៗ

X

X X

ជាការប្រពៃណាស់ដែលលោកម្ចាស់បានដាក់បញ្ហាមកនេះ

១– នៅក្របទស្សនាវដ្ដីលេខ១-២ ដែលគ្មានកាលបរិច្ឆេទកំណត់នោះ ព្រោះខ្ញុំព្រះករុណាបានសន្មតិថាសញ្ញាធំសាសនាមានកាន់ទៀននេះគឺប្រចាំឆ្នាំ១៩៥៦ តែប៉ុណ្ណោះ

ហើយលេខ១ជាគ្រឿងសំគាល់នៃខែទី១ លេខ២សំគាល់ថាខែទី២, បំពោះការចុះថ្ងៃ-ខែ-ឆ្នាំ ក៏ជាប្រយោជន៍មួយសំខាន់បំផុត តែថាបើខ្ញុំព្រះករុណាឲ្យសញ្ញាក្រុបប្រចាំឆ្នាំនឹងលេខប្រចាំខែទៅហើយចាំបាច់ដាក់ថ្ងៃ-ខែធ្វើអ្វីទៀត !

២– រូបក្រុបនេះនឹងដំកល់ទុកអស់រយៈពេល១២ខែ ការដំកល់សញ្ញាក្រុបក្នុង១ឆ្នាំនេះមិនមែនជាការពាល់គំនិតនោះទេ តែដោយយល់ឃើញដល់ថវិកាទន់ខ្សោយនៃសមាគមយើង ហើយមិនអាចនឹងបំណាយប្រាក់ឲ្យហួសចំនួនបាន ព្រោះដម្លៃគ្លិសេគ្រាប់មួយៗមានសន្ទុះដល់ទៅជាងមួយពាន់រៀល តែថាបើមិត្តអ្នកអានភាគច្រើនបេះតែបបួលគ្នាយល់ទាស់បែបនេះតទៅ ក៏ខ្ញុំព្រះករុណាយកសេចក្តីជូនគណៈកម្មការវិនិច្ឆ័យតាមការគួរដែរ ។

សូមព្រះគុណម្ចាស់ជ្រាបដោយគោរព

បណ្ណាធិការ

---

## រចនាវិលាសវាក្យភាសាអង់គ្លេស (ត)

## LESSON ONE

### I- To blow out

(To explode; to go flat; said generally of tires (=tyres))

1- On our trip to Ankor watt, one of our tires BLEW OUT.

2- If a tire BLOWS OUT while one is driving at high speed, it can be very dangerous.

## សជ្ឈាយនៈទី១

បែក; របើក; ធ្លាយ; ប្រើនិយាយបំពោះកៅស៊ូកង់រថ;

ក្នុងពេលធ្វើដំណើរទៅអង្គរវត្ត កៅស៊ូកង់រថយន្តយើងបានធ្លាយម្ខាង ។

ប្រសិនបើកៅស៊ូកង់មួយធ្លាយក្នុងពេលដែលគេកំពុងបរយ៉ាងលឿន នោះនឹងអាចមានគ្រោះថ្នាក់យ៉ាងធំ ។

## II- To turn down

(To reduce in speed or volume, to raject).

1- Please, TURN DOWN the radio; it is too loud.

2- His application for a position with that company was TURNED DOWN.

3- William tried to join the navy, but was TURNED DOWN because of his poor eyesight (អាយ-សៃត៍)

## III— To turn in

(To return; to go to bed; to slant inwards)

1- The soldier TURNS IN all his equipment on leaving the army.

2- Eleven o'clock! Let's (= let us) TURN IN.

បន្ទន់ឬបន្ថយល្បឿនឬទំហំ; បដិសេធ;

មេត្តាបន្ទន់វិទ្យុបន្តិចទៅ! វាឮខ្លាំងណាស់ ។

ពាក្យសុំរបស់គាត់ដើម្បីដំណែងមួយក្នុងបរិស័ទ (សមាគមជំនួញ) នោះត្រូវគេបដិសេធចោល ។

វិល្លាម ព្យាយាមសុំចូលកងទាហានជើងទឹក, ប៉ុន្តែត្រូវគេបដិសេធ ព្រោះចក្ខុបសាទរបស់គាត់ខ្សោយ (មិនល្អ) ។

បញ្ជូនត្រឡប់; ចូលទៅដេក; វៀនប្ដងចូលក្នុង;

ទាហាននោះបញ្ជូនត្រឡប់ នូវគ្រឿងឧបករណ៍ទាំងអស់របស់គាត់ នៅពេលដែលលាចេញពីកងទ័ពជើងទឹក ។

ម៉ោង១១ហើយ, ចូរយើងនាំគ្នាចូលដេក ។ (នៅមានត)

# រឿងតុក្កតាធ្វើពីទធិជាតិ(ត)

## ពាក្យជំអូញនៃស្វា

ប្រាំខែ, ក្រោយដែលទ្រង់មិនស្រួលព្រះទ័យនឹងព្រះនាងសុខរ៉ានី, ស្វាក៏ចូលទៅគាល់ព្រះមហាក្សត្រ

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា: «តើស្វាឯងបានដំណឹងអ្វីមកប្រាប់យើងឬ?»

ស្វាក៏ច្រៀងក្រាបទូលព្រះមហាក្សត្រថា

| | | |
|---|---|---|
| មហារាជ, | ទូលបង្គំ | មកក្រាបទូល |
| ត្រៀមព្រួយមួល | លំបាកមាំ | ទុក្ខរ៉ានី |
| មិនដល់ស្អែក | ព្រះនាងស្អាង | អស់ជីវី |
| សូមអញ្ជលី | ថ្វាយបង្គំ | ព្រះបមភព |
| ព្រះនាងមាន | អង្ករក្តាប់ | បិត្តកលក្តៅ |
| សម្បុរស្លៅ | ប្រាសក្តីសុខ | ខ្មៅព្រួយយប់ |
| សូមមេត្តា | នាងទទ់ទឹង | ភ័ក្ត្រខ្មៅជ្រប់ |
| ទ្រង់ជួយជប់ | ជន្មាយុ | បានយឺនយូរ ។ |

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលឆ្លើយតបស្វាថា ៖

« ស្វា, យើងមិនដឹងទេរឿងនេះ? »

ហើយព្រះមហាក្សត្រទ្រង់ងាកទៅខាងនាយករដ្ឋមន្ត្រីហើយត្រាស់បង្គាប់ថា :

—« លោកនាយក ឲ្យលោកចាត់ចែងក្រយ៉ា (បាយ) ដែលមានគុណសម្បត្តិដ៏ថ្លៃថ្លាតម្កល់នឹងជាសមាសដ៏វិចិត្រជូនទុក្ខរ៉ានីផង; នឹងសម្ការ (Karis) (១) ហាសិបយ៉ាង

---

(១)— ការី:ម្ហូបប្រជាជាតិ:ការីធ្វើនឹងមច្ចជាតិ,បន្លែ.គមភ្លោត,ទំពាំង ។ល....

មានឱជាសេដ្ឋេស ៗ គ្នា តម្កល់នៅកន្លែងព្រះសុវណ្ណភាជន៍; ចូរលោកទៅប្រាប់ពួកពិសេសថា តាំងពីថ្ងៃនេះតទៅ, ព្រះនាងគុក្កានីត្រូវសោយព្រះក្រយាហារមានវិសេសលក្ខណៈដូចព្រះស្ងោយរបស់យើង, ដែលយើងសោយជាដរាបមក ៗ អញ្ជើញលោកនាយក, ហើយយកប្រាក់មួយពាន់កហាបនៈ (Mohocers) (១) មាស ប្រគល់ឲ្យទៅស្វានេះ, មុននឹងវាចាកចេញពីព្រះរាជមន្ទីរ,

លោកនាយករដ្ឋមន្ត្រីក៏ធ្វើតាមព្រះរាជឱង្ការនៃព្រះមហាក្សត្រដែលទ្រង់ត្រាស់បង្គាប់ទាំងប៉ុន្មាន ៗ ស្វាក៏ក្រាបថ្វាយបង្គំលាមហារាជចាកចេញពីព្រះរាជមន្ទីរ; ស្វានោះលោតពីរជង់ហើយបង្វិលខ្លួនទៅវិញទៅមកដល់ទៅស្និតជិតព្រះនាងគុក្កានី ៗ

ខួមបឹ

ព្រះរាជិនីច្បងទ្រង់មានបន្ទូលសួរទៅស្វាថា: «ថ្ងៃនេះ, ឯងទៅឯណាបាត់? មាតាបានរង់ចាំនាងយូរណាស់មកហើយ, មាតាមិនបានទៅធ្វើតទឹកឬរៀបចំម្ហូបអាហារបរិភោគទេ; តើកាលណាយើងនឹងបរិភោគបាយព្រឹក...ៗ

ស្វាក្រាបទូលព្រះមាតាវិញថា: «ឱព្រះមាតា, សូមទ្រង់ព្រះសណ្ដាប់ទូលបង្គំ ៗ ព្រះមាតាទ្រង់មិនចាំបាច់ទៅធ្វើម្ហូបអាហារទេ:

| | | |
|---|---|---|
| ព្រះមាតា | ប្រកបយស | ថ្កើងប្រពៃ |
| សូមជោគជ័យ | បន្តិចទៀត | មានទាសា |
| ដប់ប្រាំមួយ | សួយភាជន៍មាស | ពីសេមា |
| ដាក់បាយណា | ក្ដៅសោភ័ណ | ឈ្ងុយឈ្ងប់អង្គ ៗ |

(១)–មូហ៊ួរ, Mohours រូបិយវត្ថុមានតម្លៃស្មើនឹងលុយមាស

មាន់ការី ហាសិបមុខ ឆ្ងាញ់ពិសា ។
ល្អស្អាត សុវណ្ណភាជន៍ ឆ្លាក់បញ្ចង់
យកមកជូន ព្រះមាតា ចិត្តស្មោះត្រង់
ព្រះទ័យចង់ សោយសប្បាយ តាមប្រាថ្នា ” ។

(នៅមានត)

# ជ័យប្រាជ្ញ (ត)

អាមាត្យកាន់តែមានសេចក្តីភិតភ័យខ្លាំងឡើង និយាយទៅកាន់កុមារជ័យវិញថា បើដូច្នេះអ្នកឯងត្រូវឲ្យបងទៅត្រង់ណាវិញ ។

កុមារជ័យ-មិនអីទេ! លោកកុំភ័យ! សូមអញ្ជើញទៅក្រោមគុម្ពស្នួនបញ្ជារឯណោះសិនទៅ កុំឲ្យគេមករកឃើញនៅទីនេះ ។

អាមាត្យរត់ទៅក្រោមស្រុបគុម្ពស្នួនបញ្ជារនោះឥតហ៊ានងើបឡើយ ។

កុមារជ័យ មិនអីទេលោក! សូមនៅសម្ងំឲ្យតែស្ងៀម ចាំខ្ញុំទៅប្រាប់អ្នកមេនាងសុទ្ធ្រីឲ្យអញ្ជើញមកជួបនៅទីនេះ ។

អាមាត្យ-អើ! អ្នកឯងទៅចុះបងសម្ងំចាំនៅទីនេះ ។

កុមារជ័យបានរត់ទៅមួយសន្ទុះហើយត្រឡប់មកវិញ ប្រាប់អាមាត្យនោះថា ឥឡូវនេះអ្នកមេនាងសុទ្ធ្រីព្រះមហាក្សត្រទ្រង់ត្រាស់ហៅឲ្យទៅគាល់បាត់ទៅហើយ បើយ៉ាងនេះខ្ញុំមិនដឹងធ្វើយ៉ាងម៉េចទេ ។

អាមាត្យ- ណ្ហើយចុះ! កុំបារម្ភពីរឿងនោះ សូមអ្នកឯងអាណិតមេត្តាជួយបងឲ្យ

ខាងតែរួចគ្រោះថ្នាក់ក្នុងគ្រានេះដូចម្ដេច ព្រោះថាកាលណាមានគេឃើញ មុខជាព្រះមហាក្សត្រនឹងយកទោសដល់ជីវិតមិនខាន ។

កុមារជ័យ សូមលោកនៅឲ្យតែស្ងៀមចុះ ចាំខ្ញុំទៅស្ដាប់ដំណើរការមើល តើនឹងមានហេតុភេទយ៉ាងណាទៅទៀត ។

អាមាត្យ បងសូមផ្ញើជីវិតលើអូនឯងហើយអូន! សូមអាណិតមេត្តាជួយបងផង ។

កុមារជ័យ សូមលោកកុំភ័យ! ចាំខ្ញុំទៅស្ដាប់ដំណើរការមើលសិន បើមានហេតុភេទដូចម្ដេច ខ្ញុំនឹងត្រឡប់មកការពារលោកវិញ ។

អាមាត្យ ស្រេចតែអូនឯងចុះ ។

កុមារជ័យក៏រត់ទៅកាន់ទីសំណាក់របស់អ្នកមេនាងកន្យា ក៏ត្រឡប់មកវិញប្រាប់អាមាត្យនោះថា លោកអើយ! អ្នកមេនាងកន្យាឡូឡាខ្លាំងណាស់ ថាគាត់ទៅបន្គន់អម្បាញ់មិញនេះ ឃើញមនុស្សរត់ស្ទូរទៅត្រង់ទីងងឹតដែលលោកទៅពួនសម្ងំជាដម្បូងនោះ ។

រឿងនេះមើលទៅគាន់មិនស្រួលមែនទែនហើយលោក! បើដូច្នេះសូមលោកប្រឹងនៅក្រាបឲ្យស្ងៀមចាំខ្ញុំយកសម្រាមមកចាក់ពីលើគ្របឲ្យជិតកុំឲ្យគេមករកមើលឃើញ ។

អាមាត្យនោះក៏ខំប្រឹងនៅសម្ងំស្ងៀម កុមារជ័យទៅកើបយកសម្រាមដែលគេបោះគរជាគំនរមកចាក់ហើយយកសម្រាមដែលនៅក្នុងធុង មានសម្បកចេក សម្បកស្វាយ នឹងកន្ទួចបន្ទុះស្រកាត្រីជាដើមមកចាក់ត្រួតពីលើសម្រាមទាំងនោះទៅទៀត ។ ហូរហៀរទឹកសំអុយធ្លាក់ទៅលើខ្លួនអាមាត្យនោះជោកទាំងអស់

អាមាត្យចេះតែទ្រាំរត់មិនហ៊ានហើបមាត់ហើបកឡើយ ។ លុះពេលទៀបភ្លឺ

ទ្វារព្រះបរមរាជវាំងជិតបើកហើយ កុមារជ័យរត់ទៅប្រាប់អាមាត្យនោះ ឲ្យចេញពីគំនរសម្រាមមក លូនសសៀតាមកំផែងខាងត្បូងខាងក្នុង មកក្រាបនៅក្បែរសសរក្លោងទ្វារខាងក្នុង ដែលមានគុម្ពផ្កាម្លិះមួយគុម្ពយ៉ាងស្រុំទ្រុម ៗ លុះអ្នកចាំទ្វារមកដល់ហើយ កុមារជ័យបាននិយាយនឹងអ្នកចាំទ្វារនោះថា យប់មិញនេះខ្ញុំឃើញមានសត្វអ្វីក្តី ៗ ប៉ុនពន្លឺអំពិលអំពែកនៅក្នុងគុម្ពស្មៅត្រង់នោះ មុនដំបូងខ្ញុំស្មានតែអំពិលអំពែក លុះសំឡឹងមើលទៅខ្ញុំឆ្ងល់ត្រង់ពន្លឺនោះនៅហ្នឹង មិនបានភ្លឹមភ្លែតដូចជាពន្លឺអំពិលអំពែកសោះ គឺដូចជាពន្លឺរបស់អ្វីមួយដែលគ្មានវិញ្ញាណ ខ្ញុំហៀបនឹងលូកដៃចាប់ តែខ្ញុំត្រឡប់ទៅជាមិនហ៊ានចាប់ទៅវិញ ព្រោះក្រែងពន្លឺនោះជាពន្លឺអាបព្រាយ ៗ (នៅមានត)

---

# បុណ្ណកុមារ

(៣)

វស្សុកៈនឹងនាយទាហានច្រើននាក់ទៀតស្ទុះចូល មកគ្រាហ៍យកសពលោកមេទ័ពទសយុទ្ធចេញពីបរិវេណទៅយ៉ាងប្រញាប់ . . .

ដំណឹងនៃការស្លាប់លោកមេទ័ពទសយុទ្ធ .... ស្លាប់ដោយថ្វីដៃរបស់បុណ្ណមាណព បានឮសុះសាយខ្ទរទៅពេញទាំងកងទ័ព .... ការបែកទ័ពក៏កើតឡើង....

ទាហាននៃទេវគីរីនគរចាញ់ប្រៀបគេ កំពុងតែដកថយរត់រាយគ្មានរបៀបបែបផែន រត់ដាច់តែគ្នាឯងស្លាប់ដូចគេហាល ....

សត្យាទរៈកុមារពីនិត្យឃើញដូច្នោះ ក៏ទ្រង់បញ្ជាឲ្យពួកទាហានបើកទ្វារនគរដេញ

តាមប្រយុទ្ធ ទាហាននៃទេវគីរីនគរដែលកំពុងតែរត់បែកខ្ញែកគ្នានោះ ក៏ត្រូវពួកទាហាននៃកល្យាណីបុរៈនគរដេញតាមកាប់សម្លាប់ចោលស្ទើរតែអស់ ។

សត្យាទរៈកុមារក៏ទ្រង់គង់លើទីនាំងសេះបំផាយដេញតាមសត្រូវដែរ ហើយមកទាន់ខ្មាំងមួយពួកធំដែលមានវិស្សុកៈនៅកណ្ដាលក្រុមនោះដែរ លុះវិស្សុកៈងាកមកឃើញសត្យាទរៈដូច្នោះ ក៏ស្មានថាជាបុណ្ណមាណព ព្រោះរូបកាយមុខមាត់ដូចគ្នា ។ វិស្សុកៈខាំធ្មេញឈានដោយការក្រោធខឹងទាញបង្វៀរសេះឲ្យបែរមកក្រោយវិញ ព្រមទាំងស្រែកថា

« អាបុណ្ណ ! អាកូនអ្នកសុំទាន ! អានេរគុណ ! អាឯងនឹងស្លាប់ព្រោះការនេរគុណរបស់អាឯងឥឡូវនេះជាមិនខាន ! . . . »

សត្យាទរៈស្រឡាំងកាំងនៅមួយសន្ទុះ ហើយក៏នឹកបានថាខ្លួនមានលក្ខណៈស្រដៀងនឹងបងខ្លួន ដែលអាចធ្វើឲ្យពួកទាហានខ្មាំងស្មានខុសថាជាបុណ្ណមាណពឬសត្យយុទ្ធ ។ សត្យាទរកុមារមិនបានឆ្លើយថាអ្វី គ្រាន់តែញាក់សេះឲ្យចូលសំដៅទៅរកវិស្សុកៈយ៉ាងរហ័ស ឯវិស្សុកៈក៏ចូលមកដែរដោយកំហឹងអារម្មណ៍ក្រេវក្រោធបានធ្វើឲ្យវិស្សុកៈក្រពុលមុខចូលមកប្រយុទ្ធដោយឥតប្រងប្រយ័ត្ន មិនយូរប៉ុន្មានវិស្សុកៈក៏ភ្លាត់ស្នៀតត្រូវនឹងសត្យាទរៈចាក់ត្រូវចំថ្ពាល់ខាងឆ្វេងហូរឈាមរហាម ។ វិស្សុកៈឈឺចិត្តខ្លាំងជាងឈឺស្នាមរបួស ព្រោះសត្យាទរៈសើចព្រមទាំងស្រែកបំអកឲ្យថា

« អញមិនមែនបុណ្ណមាណពទេ ! ឯបុណ្ណមាណពជាបងរបស់អញនោះ មិនមែនជាមនុស្សនេរគុណដូចសម្លាញ់ឯងថានោះទេ ! »

វិស្សុកៈនឹកឆ្ងល់ក្នុងចិត្តនៅពេលដែលបានឮដូច្នេះ ហើយក៏ញាក់សេះបំផាយគេចទៅចូលក្នុងចំណោមនៃពួកទាហានខ្លួនទៅ ។

ក្នុងទីបំផុតកងទ័ពនគរទេវគិរីក៏បរាជ័យ ខូចបង់មេទ័ពម្នាក់និងរបួសស្លាប់ជាច្រើន លុះប្រមូលប្រជុំប្រឹក្សាគ្នាទៅក៏ឃើញថាមិនអាចនឹងធ្វើដំណើរការសង្គ្រាមតទៅទៀតបាន ក៏ដកកងទ័ពថយវិលត្រឡប់ចូលទៅកាន់ទេវគិរីនគរវិញ ។ សត្យាទេវរាជកុមារបានលើកទាហានដេញតាមទៅទាល់តែដល់ទល់ដែន លុះឃើញថាពួកខ្មាំងគេចកៀសខ្លួនចេញទៅឆ្ងាយហើយ ក៏លើកទ័ពចូលមកកាន់បុរីវិញ នាកណ្ដាលការស្រែកថ្វាយពរជ័យរបស់ប្រជាជន ដែលចេញមកទទួលយ៉ាងណែនណាន់តាន់តាប់...

ឯបុណ្ណមាណពឬសត្យយុទ្ធរាជកុមារ លុះឮថាលោកមេទ័ពទសយុទ្ធឪពុកចិញ្ចឹមដែលមានគុណជាទម្ងន់លើខ្លួនស្លាប់ក្នុងទីសមរភូមិដូច្នោះ ក៏យំសោកសៅកន្ទក់កន្ទេញមិនទឹកនាដល់បាយទឹក ។ ព្រះរាជបិតានិងសត្យាទេវរាជអនុជក៏ចេះតែលួងលោមជានិច្ច តែក៏មិនអាចធ្វើឲ្យសត្យយុទ្ធរសាយទុក្ខទៅបាន ។

កងទ័ពនៃទេវគិរីនគរដែលបែកទ័ពទៅនោះ លុះធ្វើដំណើរប្រហែលជាពីរអាទិត្យក៏បានមកដល់នគរវិញ ។ ការបរាជ័យម្ដងនេះបានខូចខាតស្លាប់បង់ទាហានជាច្រើនរួមទាំងលោកមេទ័ពទសយុទ្ធដែលជាបុគ្គលដ៏សំខាន់ម្នាក់ទៀតផង ហើយបុណ្ណមាណពបុគ្គលដែលវិស្សុកៈនឹងពួកពលដែលរស់រួចពីសេចក្ដីស្លាប់ទាំងឡាយដេរដាសាថាជាមនុស្សនេរគុណនឹងជាចារបុរសរបស់ខ្មាំងសត្រូវ ។

ចំណែកខាងនាងកុសលាបានតែខំយំសោកតែម្យ៉ាង ព្រោះនាងខាតបង់ទាំងឪពុកនិងទេវបុត្រជាទីស្នេហាទៅព្រម ៗ គ្នាគួរឲ្យអាសូរនាងដែរ ! នាងយំសោកទាល់តែទឹកភ្នែកគ្រប់តំណក់ស្ទើរតែនឹងក្លាយទៅជាឈាម នាងបានឮវិស្សុកៈនិយាយថា បុណ្ណមាណពជាអ្នកបាញ់លោកមេទ័ពទសយុទ្ធឪពុករបស់នាងស្លាប់ សេចក្ដីសោកសៅក៏ក្លាយ

ទៅសេចក្ដីក្រេវក្រោធណាយទ្បំនឹងសេចក្ដីស្នេហា ព្រោះនាងស្រឡាញ់គេស្ទើរស្លាប់ មិនគួរគេតបគុណនាងបែបនេះសោះ នាងយំផងគិតផងថាប្រសិនណាបើមានឱកាសបានជួបនឹងបុណ្ណមាណពក្នុងថ្ងៃណាមួយ នាងនឹងធ្វេចក្ទុកប្រហារចោលដើម្បីបូជានូវកំហឹងនឹងសេចក្ដីស្នេហា ។ (នៅមានត)

# ប្រវត្តិក្មេងកំព្រា (ត)

ពីរថ្ងៃមកហើយសំណាងត្រូវទទួលវេទនាបែបនេះ សូម្បីទឹកមួយដំណក់ចូលដល់ពោះក៏គ្មានឡើយ ហើយមិនមានសង្ឃឹមដល់ការរស់រានមានជីវិតទៅមុខទៀតទេ គឺជឿជាក់ក្នុងចិត្តថាអាត្មាអញនឹងស្លាប់ជាប្រាកដ បើសិនជារាត្រីមួយបានកន្លងផុតទៅទៀត ។

គួរឲ្យចំឡែកណាស់ក្នុងពេលដែលសំណាងកំពុងតែសន្ទប់ ក្នុងចំណងផ្អោបគល់ឈើធំ ពេលនោះស្រាប់តែមានកងរក្សាខេត្តមួយក្រុម កំពុងតែដើរប្រពាតនាទីកោះនេះ ក្នុងចំណោមនោះគេឃើញដង្ហោប្រសើរ នឹងនារីធនសាវឿនដើរជាមួយផង ដែលមានសំលៀកបំពាក់ជាឯកសណ្ឋានដើរព្រៃកាត់តម្រង់មកទីនេះ គេពុំបានដឹងថាទីនេះជាអ្វីទេ ដោយគេឃើញសំណុះជម្រំដែលសល់អំពីភ្លើងនេះ គេក៏ស្មានបានថាប្រហែលជាជម្រំនៃពួកនេសាទណាមួយ បានជាគេចង់ដឹងហេតុការណ៍នៅទីនេះ ។

លោកដង្ហោនឹងនារីធន-សាវឿនដើរបែកពីគេ តម្រង់ទៅគល់ឈើមួយដែលគេស្មានបានថា មានបង់អ្វីមួយនៅទីនោះ

«បងសំណាង!» សម្រែករបស់នារីធន-សាវឿនស្រែកឡើង ហើយក៏ដួលសន្ទប់ស្មារតីក្បាលក្នុងទីនោះទៅ

លោកជន្មើនិមិត្តតែបានដឹងច្បាស់ហើយ ក៏ចាត់កងរក្សាខេត្រទាំងអស់ឲ្យកាត់បំណាក់អ្នករងគ្រោះនេះសែងយកទៅកាន់ដម្រាំលោកនៅមាត់ទឹក ទីងសែងនារីធន-សារឿនកំពុងសន្លប់យកទៅផង

ផ្ទះតូចមួយ ដែលគេសង់ឡើងនៅមាត់ទឹក មានអាកាសត្រជាក់ទីងម្លប់ឈើគួរឲ្យរីករាយ, នៅក្នុងផ្ទះនោះ គេឃើញនារីមួយរូបកំពុងតែខ្នះខ្នែងជាទីបំផុតក្នុងការបំរើអ្នកជម្ងឺមួយរូបដែលកំពុងតែដេកស្តូកស្តឹងនៅលើគ្រែ នាងបញ្ចុកបបរទឹកក្តៅត្រជាក់សព្វយ៉ាង នាងសប្បាយចិត្តហើយរីករាយយ៉ាងក្រៃលែង

" ម្តេចបង! បានធូរស្រួលក្នុងខ្លួនបន្តិចហើយ ,, ធន-សារឿន សួរទៅអ្នកជម្ងឺ

" បើបានអូននៅដិតបងយ៉ាងនេះ មុខជានឹងស្បើយស្រឡះនៅពេលបីថ្ងៃខាងមុខទៀត ,, សំណាងឆ្លើយ

— " ខ្ញុំស្មានថាមិនបានជួបបងទេ! មើលទៅ ! ,,

— " ម្តេចក៏អូនបេះតែទន្ទឹងបងខ្លាំងម្ល៉េះ អូនដឹងទេ ថាបងជាកូនអ្នកកំសត់មួយរូបដែលគ្មានឋានៈនិងកិត្តិយស ,,

— " ខ្ញុំថាបងជាបុរសមួយរូបត្រូវមានកិត្តិយសជាងគេទាំងអស់ ,,

— " ដោយហេតុតែខ្ញុំ ..... ស៊ូនៅក្រៅមួយជីវិតបើមិនជួបនឹងបង ,,

— " ឱ ! ចុះអូននឹងទុកបងជាអ្វី? ជា .... ឬ? បងមិនស្មានថាមានកញ្ញាវាសនាដល់ទៅប៉ុណ្ណោះទេ , កុំអី ហេះអូន! ក្រែងនាំអូនខ្មាសគេព្រោះតែបងជាអ្នកក្រីក្រដឹង?,,

— " នេះជាការៈរបស់អូនទេ ចិត្តអូនបានបង្គាប់រួចមកហើយ បើស្និទជាបងមានការស្មោះនឹងអូនមែន ! ( ទៅមានត )

រោងពុម្ពអរិយ
នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥